Tips

# ការណែនាំ៖ តើខ្ញុំអាចឈប់ដាក់ខ្លួន នៅដាច់ដោយឡែកនៅពេលណា?



## ខ្ញុំគិត ឬដឹងថា ខ្ញុំមានជំងឺ COVID-19 ហើយខ្ញុំមានរោគសញ្ញា។ តើខ្ញុំអាចឈប់ដាក់ខ្លួននៅដាច់ដោយឡែកនៅពេលណា?

អ្នកអាចនៅក្បែរអ្នកដទៃបន្ទាប់ពី៖

- រយៈពេល 10 ថ្ងៃគិតចាប់តាំងពីអ្នកចេញរោគសញ្ញាលើកដំបូង និង
- រយៈពេល 24 ម៉ោងដោយគ្មានជំងឺគ្រុនក្ដៅ និង
- រោគសញ្ញា COVID-19 របស់អ្នកបានធូរស្រាល។




## ប្រសិនបើខ្ញុំគ្មានរោគសញ្ញាទេតើខ្ញុំត្រូវដាក់ខ្លួននៅដាច់ដោយឡែករហូតដល់ចប់រយៈពេលកំណត់ដែរឬទេ?

ត្រូវហើយ! បុគ្គលមួយចំនួនដែលធ្វើតេស្តវិជ្ជមាន COVID-19 ពុំមានរោគសញ្ញាណាមួយឡើយ ប៉ុន្តែនៅតែអាចចម្លងវីរុសទៅអ្នកដទៃ។ សូមស្នាក់នៅផ្ទះ និងនៅឆ្ងាយពីអ្នកដទៃរហូតដល់ផុតរយៈពេល 10 ថ្ងៃ គិតចាប់ពីថ្ងៃដែលអ្នកបានធ្វើតេស្តវិជ្ជមាន។

## ខ្ញុំបានចាក់វ៉ាក់សាំងពេញលេញហើយតើខ្ញុំត្រូវនៅដាច់ដោយឡែករហូតដល់ចប់រយៈពេលកំណត់ដែរឬទេ?

ត្រូវហើយ!វ៉ាក់សាំងពុំមានប្រសិទ្ធភាព100%ក្នុងការការពារជំងឺ COVID-19ឡើយ។នៅមានភាគរយតិចតួចដែលបុគ្គលទទួលការចាក់វ៉ាក់សាំងពេញលេញចេញរោគសញ្ញាដោយសារ COVID-19 ឬធ្វើតេស្តវិជ្ជមាន ប៉ុន្តែពុំមានរោគសញ្ញា។







### ថ្ងៃសូន្យ (0) គឺជាថ្ងៃទីមួយដែលអ្នកចេញរោគសញ្ញា ឬថ្ងៃដែលបានធ្វើតេស្ត។ នៅថ្ងៃទី 11 អ្នកអាចចាកចេញពីការដាក់ខ្លួននៅដាច់ដោយឡែកបាន។*

*អ្នកពុំចាំបាច់ត្រូវធ្វើតេស្តអវិជ្ជមានដើម្បីចាកចេញពីការដាក់ខ្លួននៅដាច់ដោយឡែក ឬត្រឡប់ទៅធ្វើការវិញឡើយ។*

**បុគ្គលមួយចំនួនតូចគួរដាក់ខ្លួននៅដាច់ដោយឡែករយៈពេល 20 ថ្ងៃ នៅពេលមានការណែនាំពីវេជ្ជបណ្ឌិតរបស់ពួកគេ។*


**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

**Colleen Chawla** – Agency Director
**Kimi Watkins-Tartt** – Director
**Nicholas Moss, MD** – Health Officer

Contact
Public Health Department:
(510) 267-8000 Main Line
COVID-19 Information:
(510) 268-2101
www.acphd.org